អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អូស្ត្រាលីប្រកាសសន្យាផ្តល់ជំនួយថវិកាបន្ថែមចំនួន ១,៦១ លានដុល្លារអូស្ត្រាលី

រដ្ឋាភិបាលអូស្ត្រាលីបានប្រកាសសន្យាផ្តល់ជំនួយថវិកាបន្ថែមចំនួន ១,៦១ លានដុល្លារអូស្ត្រាលី (ប្រមាណ ១,៧៣ លានដុល្លារអាមេរិក) ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ ថវិកាចំនួន ១ លានដុល្លារអូស្ត្រាលី នឹងត្រូវផ្តល់ជូនទៅភាគីអន្តរជាតិ ហើយ ០,៦១ លានដុល្លារអូស្ត្រាលី នឹងត្រូវផ្តល់ជូនទៅភាគីជាតិនៃ អ.វ.ត.ក។ ការសន្យាផ្តល់ជំនួយបន្ថែមនេះត្រូវបានប្រកាសដោយរដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី និងជាសមាជិកព្រឹទ្ធសភា ឯកឧត្តម បប់ ខារ នៅក្នុងដំណើរទស្សនកិច្ចរបស់ឯកឧត្តមនៅ អ.វ.ត.ក នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២។

ឆ្លើយតបនឹងជំនួយសប្បុរសនេះ ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូសិនហក អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក បានថ្លែងថា៖ "អ.វ.ត.ក សូមសម្តែងអំណរគុណដល់រដ្ឋាភិបាលអូស្ត្រាលី ដែលមានទឹកចិត្តសប្បុរសបន្តការគាំទ្រចំពោះ អ.វ.ត.ក ក្នុងការស៊ើបអង្កេតនិងជំនុំជម្រះសេចក្តីលើឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម។ ជំនួយរបស់អូស្ត្រាលីនៅពេលនេះគឺជាអំណោយដ៏ថ្លៃថ្លា ដែលចូលរួមចំណែកឲ្យ អ.វ.ត.ក អាចបន្តការងារដើម្បីបំពេញអាណត្តិរបស់ខ្លួនក្នុងការនាំយកយុត្តិធម៌ជូនប្រជាជនកម្ពុជា។"

អូស្ត្រាលីគឺជាប្រទេសម្ចាស់ជំនួយធំមួយក្នុងចំណោមប្រទេសម្ចាស់ជំនួយធំៗនានា ដែលបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់ដំណើរការរបស់ អ.វ.ត.ក តាំងពីចាប់ផ្តើមបង្កើតដំបូង។ បូករួមទាំងជំនួយលើកនេះផង អូស្ត្រាលីបានផ្តល់ជំនួយថវិកាសរុបចំនួន ១៨,៣ លាន ដុល្លារអូស្ត្រាលី ដើម្បីចូលរួមចំណែកក្នុងការពង្រឹងយុត្តិធម៌អន្តរជាតិ ការផ្សះផ្សាជាតិ និងកេរដំណែលយុត្តិធម៌នៅកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥(0) ២៣ ៨១៤ លេខបន្ទ: ៦១៦៩
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥-១២ ៤៨ ៣២៨៣
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh